# ការសង្ខេបវេយ្យាករណ៍ខ្មែរ SUMMARY OF KHMER GRAMMAR

1. **របៀបប្រើវណ្ណយុត្តិ ៖**

   ( ៌ ) ហៅថារបាទ ឬរេផៈក៏បាន -ធ្វើឲ្យអក្សរតួដើមបន្ទាប់ មានសូរសំឡេងញ័រ ដូចជា ៖ ទុគ៌ត, បូព៌ា, ធម៌ ។

   ( ៍ ) ហៅថាបដិសេធ ឬទណ្ឌឃាតក៏បាន -សំរាប់ដាក់ឃាត់អក្សរដែលជាប់មកពីបាលី ឬសំស្ក្រឹត មិនឲ្យមានសំឡេង ដូចជា ៖ វិសេសន៍, ទេសចរណ៍, ប្រយោជន៍, បដិវត្តន៍, ប្រសាសន៍ ។ សូមកុំភាន់ច្រឡំជាមួយនឹងលេខអស្តាឲ្យសោះ ។

   ( ៏ ) ហៅថាលេខអស្តា -ជាវណ្ណយុត្តិមួយបែប មានសណ្ឋានដូចជាលេខប្រាំបី សំរាប់ប្រើដាក់លើអក្សរទោល នាំឲ្យក្សរនោះឲ្យមានសំឡេងកញ្ឆក់ខ្លីរហ័ស ដែលច្រើនតែប្រើនៅលើអក្សរ ក, ដ, ន ហើយនិងហ ដូចជា ៖ ក៏ទៅ, ក៏ដោយ, ដ៏ប្រពៃ, ដ៏ឧត្តម, អុញ្ញន៏ ។

2. **របៀបប្រើក្បៀសសញ្ញា ( , )** តាមវេយ្យាករណ៍ខ្មែរ គេតែងនិយមប្រើដើម្បីចែកការពន្យល់ ដូចជា ៖ ទង់ជាតិខ្មែរមានបីពណ៌ គឺ : ក្រហម, ខៀវ និងស ។ ប៉ុន្តែតាមធម្មតា គេប្រើដកឃ្លាវិញ បើសិនវាមិនមែនជាការពន្យល់ ឬបញ្ជាក់ឲ្យច្បាស់លាស់ទេនោះ ។

3. **តើនៅពេលណាត្រូវប្រើស្រៈអិ ( ិ )?** បើអ្វីបូកបញ្ចូលគ្នា ត្រូវប្រើស្រៈ ិ ឧទាហរណ៍ ៖ អ្នកនិងខ្ញុំ, កាំបិតនិងពូថៅ, កូនឈ្នួលនិងថៅកែ *ដែលស្មើនឹង AND នៃភាសាអង់គ្លេស ។*

4. **តើនៅពេលណាត្រូវប្រើស្រៈអឹ ( ឹ )?** ត្រូវប្រើបើសិនជាការនោះនឹងកើតឡើងនៅអនាគត ឬជាប់ជាមួយ ឧទាហរណ៍ ៖ ខ្ញុំនឹងទៅផ្សារ, ខ្ញុំនឹងស្លាប់, កាប់ឈើជាមួយនឹងពូថៅ, *គ្រូពេទ្យជួបជាមួយនឹងអ្នកជំងឺ ស្មើនឹង WILL ឬ WITH ។*

5. **របៀបប្រើស្រៈអេះ (េះ)** -ចូរកុំយករះមុខដែលភាគច្រើនប្រើនៅខាងក្រោយអក្សរ(ណ)និងអក្សរ(វ) ឲ្យសោះ ដូចជា ៖ លក្ខណៈ, វណ្ណៈ, ភារៈកិច្ច ។ គឺត្រូវតែសរសេរបែប (នេះ) មិនមែន (នេ:) ទេ ហើយស្រៈអោះក៏ត្រូវតែសរសេរ (ោះ) មិនមែន (ោ:) ឡើយ ។

6. **របៀបប្រើខ័ណ្ឌសញ្ញា ( ។ )** ខ័ណ្ឌសញ្ញាប្រើសំរាប់បញ្ចប់ឃ្លាឬវគ្គ *ដែលស្មើនឹង PERIOD ភាសាអង់គ្លេស ។ តាមធម្មតា ត្រូវដកឃ្លាមុនដាក់ខ័ណ្ឌសញ្ញា ហើយក៏ត្រូវដកឃ្លាបន្ទាប់ពីខ័ណ្ឌដែរ មុននឹងចាប់ផ្តើមវគ្គមួយទៀត ដើម្បីឲ្យស្រឡះមើល ។ យើងអាចរកឃើញរបៀបសរសេរក្នុងវចនានុក្រមខ្មែរ ។ បើគ្មានកន្លែងគ្រប់គ្រាន់អាចដកឃ្លាទេ ឬដើម្បីកុំឲ្យពួកបរទេសសួរច្រើនពេក មិនបាច់ដកឃ្លារួចដាក់ខ័ណ្ឌឡើយ។* ***ប៉ុន្តែជាដាច់ខាត ត្រូវតែដកឃ្លាពីរដងបន្ទាប់ពីខ័ណ្ឌសញ្ញា។*** *តាមបទពិសោធន៍របស់ខ្ញុំក្នុងការបកប្រែជាច្រើនឆ្នាំកន្លងមក ឥឡូវនេះខ្ញុំចូលចិត្តប្រើរបៀបឥតដកឃ្លាមុនដាក់ខ័ណ្ឌសញ្ញា រួចសឹមដកឃ្លាពីរដងបន្ទាប់ពីខ័ណ្ឌសញ្ញា។*

7. **របៀបប្រើយុគលពិន្ទុ ( : )** ប្រើជាគ្រឿងសំគាល់ការចង្អុលពាក្យ ឬចង្អុលសេចក្តីខាងមុខ ដែលជាឧទាហរណ៍ឬជាភស្តុតាង ។

8. **របៀបប្រើទ្វិពិន្ទុលេខ ឬចំណុចពីរគូស ( ៖ )** សំរាប់ប្រើដាក់ពីមុខសេចក្តីដែលបំរុងនឹងរៀបរាប់ ឬបំរុងនឹងអធិប្បាយ ។ តាមទំលាប់ដើមគេនិយមប្រើយុគលពិន្ទុ (:) តែក្រោយមកក៏ប្រើទ្វិពិន្ទុ (៖) វិញ ដើម្បីកុំឲ្យច្រឡំនឹងវិសជ្ជនីយឬរះមុខ (ះ) *គឺមានភាពស្រដៀងគ្នានឹងការពន្យល់នៅលេខ ២ ដែលមានអត្ថន័យស្មើនឹង COLON នៃភាសាអង់គ្លេស ។*

9. **របៀបសរសេរលេខ ។** *ខ្ញុំបានខំស្រាវជ្រាវរករបៀបសរសេរលេខឲ្យត្រឹមត្រូវ ប៉ុន្តែមិនឃើញមាននៅក្នុងសៀវភៅវេយ្យាករណ៍ណាដែលពន្យល់ពីរបៀបប្រើអាចធ្វើជាភស្តុតាងបាន ។ ទោះជាយ៉ាងណាក្តី ខ្ញុំបានរកឃើញជាច្រើនកន្លែងនៅក្នុងព្រះគម្ពីរប៊ីប "លោកុប្បត្តិ ១:៥-៣១" និងក្នុងសៀវភៅវេយ្យាករណ៍ខ្មែរផ្ទាល់ រួមទាំងកក្នុងវចនានុក្រមខ្មែរ គឺថាត្រូវដកឃ្លាមួយមុននឹងសរសេរលេខ រួចហើយក៏ដកឃ្លាមួយទៀតបន្ទាប់ពីលេខ ឧទាហរណ៍ : ថ្ងៃអាទិត្យទី ១ ខែមករា ឆ្នាំ ២០០២ ។ ភាសាអង់គ្លេសក៏ប្រើបែបដូច្នេះដែរ គឺដើម្បីញែកអក្សរនិងលេខឲ្យចេញស្រឡះពីគ្នា ។*

## ខាងក្រោមនេះគឺជាពាក្យខ្មែរខ្លះ ដែលគួរតែចាំទុកក្នុងការសរសេរ :

1. បើកិរិយាសព្ទ **បដិសេធ** ប៉ុន្តែបើវាជានាម **បដិសេធន៍** ។ 2. បើកិរិយាសព្ទ **សន្មត** ប៉ុន្តែបើវាជានាម **សន្មតិ** ។ 3. បើកិរិយាសព្ទ **អនុវត្ត** ប៉ុន្តែបើវាជានាម **អនុវត្តន៍** ។ 4. បើគុណនាម **ប្រយ័ត** ប៉ុន្តែបើវាជានាម **ប្រយ័ត្ន** *(ជាការងាយស្រួល អាចសរសេរជា**ប្រយ័ត្ន**នៅគ្រប់ពេលក៏បានដែរ)* ។
4. ចូរកុំសរសេរ **អនុញ្ញាតិ** ប៉ុន្តែត្រូវសរសេរជា **អនុញ្ញាត** វិញ ។ រីឯពាក្យ **គំរោងការ** ឬ**ផែនការ** ឥតមាន(ណ៍) ទេ គឺលុះត្រាណាតែវាជាហេតុការណ៍ ។
5. **សំនួរ** សំដេចជួន-ណាតថាយើងគួរសរសេរជា **សំណួរ** វិញ ។ **សំឡេង** មិនមែនសំលេងទេ ។ **តំណាង** ឬ**ដំណាង** មិនមែនតំនាងទេ ។

1. ការសង្ខេបវេយ្យាករណ៍ខ្មែរនេះបានដកស្រង់ចេញពីសៀវភៅ "វិធីប្រើវណ្ណយុត្តិ និងខ័ណ្ឌសញ្ញា" បោះពុម្ពលើកទី ៤ ឆ្នាំ ១៩៥៥ រៀបរៀងដោយលោក នួន-ប៊ុត ពិនិត្យដោយលោក ញ៉ុក-ថែម ។
2. ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនមែនជាអ្នកពូកែខាងអក្សរសាស្ត្រទេ ។ កាលពីមុនខ្ញុំចូលចិត្តសរសេរជាព្យាង្គជំរួត (តម្រូត ឬតំរួត) ប៉ុន្តែការនេះធ្វើឲ្យអ្នកដែលមិនសូវចេះអក្សរខ្មែរពិបាកអាន ម្ល៉ោះហើយបានជាខ្ញុំប្តូរការសរសេរតាមរបៀបព្យាង្គរាយវិញ ។ នៅទំព័រទី ៣-៤ នៃវចនានុក្រមខ្មែរ សំដេចជួន-ណាតបានចែងថា "ពុំអាចហ៊ានសំរេចជាដាច់ខាតទេ" ដ្បិតអស់លោកខ្លះបានធ្លាប់ដែសរសេរជា ដំរាប់, ដម្រាប់, តំរាប់, ឬតម្រាប់ ជាយូរមកហើយ ។ ហេតុដែលខ្ញុំហ៊ានសរសេរថាជា ដំរូវ (តម្រូវ) និងដំឡៃ (តម្លៃ) គឺខ្ញុំយកតាមលំនាំព្រះគម្ពីរប៊ីប ដែលជាសៀវភៅមួយមានមនុស្សអានច្រើនជាងគេនៅក្នុងបណ្តាសៀវភៅទាំងឡយ ។ លោកអ្នកអាចរកឃើញពាក្យទាំងពីរនេះនៅក្នុងព្រះគម្ពីរ ហេព្រើ ៩:២៧ និង ម៉ាថាយ ១៣:៤៦ សំរាប់ជាទីសំអាង ឬអានទំព័រទី ៣-៤ នៃវចនានុក្រមខ្មែរ ។
3. បើប្រើព្យាង្គជំរួតសូមកុំលាយឡំគ្នានឹងព្យាង្គរាយ ហើយព្យាង្គរាយប្រើចំហតិចជាងព្យាង្គជំរួត ។ នៅក្នុងប្រយោគនិមួយៗក៏សូមកុំសរសេរឲ្យមានឃ្លាវែងពេក ប្រយោជន៍ឲ្យស្រួលអាននិងងាយយល់ផង ។ សូមអរគុណ ។